# ជំងឺរលាកខួរក្បាលជប៉ុន

## អ្វីទៅជាជំងឺរលាកខួរក្បាលជប៉ុន?

ជំងឺរលាកខួរក្បាលជប៉ុន បង្កឡើងដោយវីរុសរលាកខួរក្បាលជប៉ុន។ ជំងឺនេះគឺធ្វើឱ្យរលាកជាលិកាខួរក្បាល ហើយជាទូទៅបង្កឡើងដោយការឆ្លងរោគ។

ជំងឺរលាកខួរក្បាលជប៉ុនឆ្លងតាមរយៈមូសខាំ ហើយវាកើតមានឡើងជាទូទៅនៅក្នុងតំបន់ដែលសកម្មភាពមូសមានការកើនឡើង។

ការឆ្លងទៅមនុស្សជាទូទៅមិនបង្ហាញរោគសញ្ញាឡើយ ប៉ុន្តែនៅក្នុងស្ថានភាពដ៏កម្រ ជំងឺនេះអាចឈានទៅរកសភាពធ្ងន់ធ្ងរ ឬក៏អាចនាំឱ្យបាត់បង់ជីវិត។

## តើវីរុសនេះឆ្លងរាលដាលដោយរបៀបណា?

វីរុសនេះឆ្លងតាមរយៈការខាំរបស់សត្វមូសដែលមានជំងឺ។ វីរុសនេះមិនអាចឆ្លងពីមនុស្សទៅមនុស្សបានឡើយ ឬក៏ដោយការទទួលទានសាច់សត្វដែលមានជំងឺនេះ។

សត្វជ្រូកនិងបក្សីព្រៃរស់នៅលើទឹក មានតួនាទីសំខាន់ក្នុងការចម្លងវីរុសនៃជំងឺនេះ។ វីរុសនេះធ្វើការបែងភាគនៅក្នុងខ្លួនសត្វជ្រូកដែលមានជំងឺ ញ៉ាំងឱ្យកម្រិតនៃការឆ្លងនៅក្នុងឈាមជ្រូកមានកម្រិតខ្ពស់។ សត្វមូសដែលខាំបឺតយកឈាមជ្រូកដែលមានជំងឺទំនងជាប្រាកដណាស់ថាបានឆ្លងវីរុសនេះ ហើយបន្ទាប់មកក៏ចម្លងបន្តទៅមនុស្សលោក។

## រោគសញ្ញានានា

រោគសញ្ញានានានៃជំងឺរលាកខួរក្បាលជប៉ុន រួមមាន៖

- ឈឺក្បាល
- គ្រុនឡើងកម្ដៅ
- ប្រកាច់ ឬប្រគ្រីវ (ជាពិសេសនៅក្នុងចំណោមកុមារក្មេងៗ)
- រឹងកញ្ចឹងក
- អារម្មណ៍ដោកងុយ
- វង្វេងភាន់ភាំង ហើយឈានទៅភាពរវើរវាយ និង
- សន្លប់បាត់ស្មារតី នៅក្នុងករណីធ្ងន់ធ្ងរ។

ជាទូទៅការធ្លាក់ខ្លួនឈឺក្រោយពីមូសខាំ មានរយៈពេលរវាងពី 5 ទៅ 15 ថ្ងៃ។

បើសិនជាអ្នកគិតថា អ្នកអាចឆ្លងវីរុសនៃជំងឺរលាកខួរក្បាលជប៉ុន  ចូរស្វែងរកជំនួយពេទ្យជាបន្ទាន់។

## ការព្យាបាល

គ្មានវិធីព្យាបាលជំងឺរលាកខួរក្បាលជប៉ុនឡើយ។ អ្នកអាចសម្រាលនូវអាការរោគទាំងនោះបាន ដោយ៖

- សម្រាកឱ្យបានច្រើន
- ទទួលទានជាតិទឹកឱ្យបានច្រើន
- លេបថ្នាំបំបាត់សិតតាម៉ុល សម្រាប់ការឈឺចុកចាប់ និងគ្រុនក្ដៅ

នៅក្នុងករណីធ្ងន់ធ្ងរខ្លាំង ការចូលសម្រាកក្នុងមន្ទីរពេទ្យដើម្បីការឃ្លាំមើលជំងឺអាចជាការចាំបាច់។

## វិធីការពារខ្លួនអ្នក

មានវិធីពីរយ៉ាង ដើម្បីបង្ការជំងឺរលាកខួរក្បាលជប៉ុន៖

1. ចៀសវាងកុំឱ្យមូសខាំ



NORTHERN TERRITORY GOVERNMENT

2. ចាក់ថ្នាំបង្ការដើម្បីទប់ស្កាត់វីរុស

អ្នកអាចការពារខ្លួនអ្នកប្រឆាំងនឹងវីរុស ដោយអនុវត្តដូចតទៅនេះ៖

- ចៀសវាងកុំទៅកន្លែងមានមូសច្រើនដែលនៅជិតវាលទំនាបជាំទឹក ជាកន្លែងដែលមានបក្សីទឹក និងសត្វជ្រូកព្រៃរស់នៅ
- ប្រើសម្លៀកបំពាក់រលុង ពណ៌ស្រាលសម្រាប់ពាក់នៅក្រៅផ្ទះដើម្បីការពារខ្លួន ហើយត្រូវគ្របបិទបាំងជើង ប្រអប់ជើង និងដៃឱ្យបានជិត។
- ចៀសវាងកុំនៅក្រៅផ្ទះ នៅពេលដែលមូសចេញធ្វើសកម្មភាព-នៅមុនពេលថ្ងៃលិចនៅក្នុងពេលរាត្រី និងព្រលឹមស្រាងៗ។
- ប្រើថ្នាំបណ្ដេញសត្វមូសសម្រាប់មនុស្ស ដែលមានផ្ទុកសារធាតុ ដាយស៊ីអាថុលលូអាមិន (diethyl toluaminde [DEET]), ពីការីឌីន (picaridin) ឬ PMD (ដែលចម្រាញ់ចេញពីដើមប្រេងខ្យល់យូកាលីបមានក្លិនដូចក្រូចឆ្មារ) ដោយបាញ់ ឬលាបថ្នាំនេះនៅលើស្បែកដែលគ្មានអ្វីបិទបាំង។
- ត្រូវមើលការពារទារកនិងកុមារឱ្យបានល្អដើម្បីកុំឱ្យមូសខាំ។
- ពេលនៅក្នុងកន្លែងឬងរោងក្រៅផ្ទះដែលមានដំបូល ឬកន្លែងមិនសូវមានខ្យល់ ចូរប្រើធូបឬទានបណ្ដេញមូសដោយការប្រើកម្ដៅឬឧបករណ៍ប្រើហ្គាសដោយមានទ្រនាប់មានជាតិថ្នាំកម្ចាត់សត្វល្អិត ។
- ធ្វើឱ្យប្រាកដថាទ្វារសំណាញ់នៅក្នុងផ្ទះ ឬខារ៉ាវេន (caravan) មានលក្ខណៈល្អ មិនរហែកធ្លុះធ្លាយ។
- ទទួលទានដំណេកនៅក្នុងតង់ការពារមិនឱ្យមូសចូលបាន ឬក៏នៅក្នុងមុងរបង្ការមិនឱ្យមូសចូលបាននៅពេលទៅបោះជំរំ
- ចាក់ចោលទឹកនៅក្នុងធុង ឬប៉ោត ដែលមូសអាចរស់នៅបង្កបង្កើនកូនចៅ។

សម្រាប់ព័ត៌មានបន្ថែម អំពីជំងឺរលាកខួរក្បាលជប៉ុនសូមមើល៖ https://nt.gov.au/wellbeing/health-conditions-treatments/viral/japanese-encephalitis

សម្រាប់ព័ត៌មានបន្ថែម អំពីជំងឺរលាកខួរក្បាលជប៉ុននៅក្នុងពពួកសត្វផ្សេងៗ ដោយរួមទាំងសញ្ញានៃជំងឺនេះ
សូមមើល៖ https://nt.gov.au/japanese-encephalitis